**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

# កំណត់ហេតុស្តីពីការប្រជុំពិនិត្យការកែលម្អតាមអនុសាសន៍សវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង សម្រាប់ការិយបរិច្ឆេទ២០២២

ឆ្នាំពីរពាន់ម្ភៃបួន ខែកញ្ញា ថ្ងៃទីដប់ប្រាំពីរ វេលាម៉ោងបីរសៀល ប្រតិភូសវនកម្មផ្ទៃក្នុងនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដឹកនាំដោយ លោក **យួន សុជាតិ** បានជួបប្រជុំគ្នាជាមួយថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ដើម្បីពិភាក្សាលើលទ្ធផលនៃការកែលម្អលើការងារដែលប្រតិភូសវនករបានពិនិត្យកន្លងមក។ សមាសភាពចូលរួមមានដូចខាងក្រោមៈ

**ក-សមាសភាពប្រតិភូសវនកម្មផ្ទៃក្នុង**

| | | |
|---|---|---|
| ១-លោក | **យួន សុជាតិ** | ប្រធានប្រតិភូ |
| ២-លោក | **ហៀក សុផារិទ្ធ** | អនុប្រធានប្រតិភូ |
| ៣-លោក | **ហេង វាសនា** | សមាជិក |
| ៤-លោក | **អ៊ុត សុផា** | សមាជិក |
| ៥-លោក | **ជា សីទ្ធវុធ** | សមាជិក |
| ៦-លោក | **នី ម៉ាល័យ** | សមាជិក |
| ៧-លោក | **រៀម នារីរ័ត្ន** | សមាជិក |

**ខ-សមាសភាពថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង**

| | | |
|---|---|---|
| ១-លោក | **លី សុភា** | ប្រធានមន្ទីរ |
| ២-លោក | **ឈុន សុខកុម្ភៈ** | អនុប្រធានមន្ទីរ |
| ៣-លោកស្រី | **ប៊ិល ច័ន្ទធា** | អនុប្រធានមន្ទីរ |
| ៤-លោក | **ផេង សុគន្ធ** | ប្រធានការិយាល័យសំណង់ |
| ៥-លោក | **អ៊ួង ថិរៈ** | អនុប្រធានការិយាល័យរដ្ឋបាល |
| ៦-លោក | **អ៊ី ថេងគី** | មន្ត្រីការិយាល័យរដ្ឋបាល |
| ៧-លោកស្រី | **ហ៊ុយ ចន្ថា** | រជ្ជទេយ្យករចំណូល |

ជាកិច្ចចាប់ផ្តើម លោក **លី សុនា** ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង បានសំដែងនូវភាពសោមនស្សដល់ប្រតិភូសវនករនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះមកតាមដានអនុសាសន៍ដែលបានផ្តល់ឱ្យកន្លងមកដល់មន្ទីរ សម្រាប់ធ្វើការកែលម្អ និងថ្លែងអំណរគុណចំពោះលទ្ធផលសវនកម្មដែលសម្រេចបាន។ បន្ទាប់មក លោកប្រធានមន្ទីរ បានប្រគល់នាទីជូនលោកប្រធានប្រតិភូសវនកម្មមានមតិបើកអង្គប្រជុំ÷

លោក **យ៉ួន សុជាតិ** ប្រធានប្រតិភូ និងជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង បានជម្រាបជូនអង្គប្រជុំថា ការចុះមកពេលនេះដោយយោងលិខិតបញ្ជាបេសកកម្មលេខ១៦២ និងលេខ១៦៣ អរប ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យពីការកែលម្អតាមអនុសាសន៍ បានចុះធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធដែលបានផ្តល់អនុសាសន៍ដូចខាងក្រោម÷

**ក.អនុសាសន៍របស់សវនកម្មផ្ទៃក្នុង÷**

១.មន្ទីរ ត្រូវជំរុញការគ្រប់គ្រងសៀវភៅចុះលេខលិខិតចេញឱ្យបានត្រឹមត្រូវគ្រប់ជ្រុងជ្រោយ។

២.មន្ទីរ ត្រូវជំរុញការគ្រប់គ្រងមន្ត្រីឱ្យបានហ្មត់ចត់ និងត្រឹមត្រូវស្របតាមអនុក្រឹត្យលេខ០៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។

៣.មន្ទីរ ត្រូវជំរុញការរៀបចំតារាងប្រៀបធៀបកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា។

៤.មន្ទីរ ត្រូវខិតខំជួយជំរុញបន្ថែម និងពន្យល់ណែនាំដល់ប្រជាពលរដ្ឋដើម្បីមកស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន-បិទការដ្ឋាននៅពេលសំណង់រួចរាល់។

**ខ.វិធានការកែលម្អរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷**

១-រដ្ឋទេយ្យករចំណូលត្រូវ÷

-ចុះកិច្ចបញ្ជិកាឱ្យបានទាន់ពេលវេលាស្របតាមប្រកាសលេខ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-អនុវត្តឱ្យពេញលេញស្របតាមលិខិតបទដ្ឋាន ស្តីពីការទូទាត់ត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈតាមប្រព័ន្ធធនាគារជាពិសេសប្រាក់រង្វាន់លើកទឹកចិត្តដែលបានទទួលពីរដ្ឋបាលខេត្ត។

២. ក្រុមលទ្ធកម្មមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមបទប្បញ្ញត្តិ និងលិខិតបទដ្ឋានពាក់ព័ន្ធលទ្ធកម្មសាធារណៈដូចជាបណ្ណប៉ាតង់អ្នកចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា ត្រូវមានប័ណ្ណប៉ាតង់នោះស្របតាមកម្មវត្ថុនៃការចូលរួម។

៣. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ត្រូវ÷
- រៀបចំតារាងកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២២ឱ្យបានទាន់ពេលវេលាស្របតាម លិខិតបទដ្ឋានគតិយុត្តនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ធ្វើស្លាកលេខម៉ូតូ Honda Dream ចំនួន០១គ្រឿង តម្លៃ ៦ ៨១១ ៣៧១ រៀល។

៤. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ត្រូវខិតខំអនុវត្តកែលម្អរាល់បណ្ដាចំណុចវិធានការដែលគណៈប្រតិភូអធិការកិច្ចហិរញ្ញវត្ថុ បានចាត់វិធានការក្នុងការិយបរិច្ឆេទសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។

បន្ទាប់មក លោកប្រធានមន្ទីរ និងមន្ត្រីជំនាញពាក់ព័ន្ធមានមតិបំភ្លឺ និងបង្ហាញឯកសារដើម្បីបញ្ជាក់ពីការកែលម្អតាមអនុសាសន៍លើកឡើងខាងលើ។ ជាលទ្ធផល ប្រតិភូសវនករ និងអង្គភាពសវនដ្ឋានបានពិនិត្យ ព្រមទាំងឯកភាពគ្នាដូចតទៅ÷

**ក. ការឆ្លើយតបចំពោះអនុសាសន៍សវនកម្មផ្ទៃក្នុង÷**

១. តាមការពិនិត្យសៀវភៅចុះលេខលិខិតចេញ-ចូលរបស់មន្ទីរឃើញថា អនុវត្តបានល្អប្រសើរដូចជាពុំមានការចុះលេខរំលង ស្ទួន និងបានបំពេញខ្លឹមសារគ្រប់គ្រាន់។

២. មន្ទីរ បានពង្រឹងការគ្រប់គ្រងមន្ត្រីស្របតាមអនុក្រឹត្យលេខ០៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ដោយមន្ត្រីនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលអវត្តមានច្រើនដងកាលពីឆ្នាំ២០២២ គាត់បានមកបំពេញការងារទៀងទាត់វិញហើយ។

៣. មន្ទីរបានរៀបចំតារាងប្រៀបធៀបកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២២ និងបានចុះហត្ថលេខាពីប្រធានអង្គភាពប្រើប្រាស់ អ្នកពាក់ព័ន្ធ និងប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង និងជាអនុប្រធានគណៈកម្មាធិការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ រួចរាល់ហើយ។

៤. មន្ទីរបានធ្វើលិខិតលេខ៧៧១ ដនសស-កឆ/លស ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ស្ដីពីសំណើសុំជួយជំរុញម្ចាស់សំណង់ ស្នើសុំលិខិតអនុញ្ញាតបើក និងបិទការដ្ឋានសំណង់ (ជូនរដ្ឋបាលក្រុង/ស្រុក

ដើម្បីជួយជំរុញ) និងបានផ្សព្វផ្សាយស្ដីពីច្បាប់សំណង់ និងណែនាំម្ចាស់សំណង់ត្រូវស្នើសុំលិខិតបើកការដ្ឋាន បន្ទាប់ពីលិខិតស្នើសុំអនុញ្ញាតសាងសង់ត្រូវបានអនុញ្ញាតពីសមត្ថកិច្ចរដ្ឋបាលខេត្ត និងបិទការដ្ឋាន (វិញ្ញាបនបត្រប្រើប្រាស់សំណង់) នៅពេលបញ្ចប់ការសាងសង់។

**ខ.ការឆ្លើយតបចំពោះវិធានការកែលម្អរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷**

១-រដ្ឋទេយ្យករចំណូលបាន÷

-ចុះកិច្ចបញ្ជិកាស្របតាមប្រកាសលេខ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានធ្វើការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តចូលគណនីបៀវត្សរបស់មន្ត្រីតាមប្រព័ន្ធធនាគាររួចហើយ។

២.ក្រុមលទ្ធកម្មមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំងបានអនុវត្តស្របតាមលិខិតបទដ្ឋានពាក់ព័ន្ធលទ្ធកម្មសាធារណៈដូចជាបណ្ណប៉ាតង់អ្នកចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា ដោយមានបណ្ណប៉ាតង់ស្របតាមកម្មវត្ថុនៃការចូលរួមដេញថ្លៃបានល្អប្រសើរហើយ។

៣.ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ÷

-មន្ទីរបានរៀបចំតារាងប្រៀបធៀបកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២២ និងបានចុះហត្ថលេខាពីប្រធានអង្គភាពប្រើប្រាស់ អ្នកពាក់ព័ន្ធ និងប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង និងជាអនុប្រធានគណៈកម្មាធិការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ រួចរាល់ហើយ។

-មន្ទីរបានធ្វើស្លាកលេខម៉ូតូ Honda Dream រួចហើយ។

៤.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង បានយកចិត្តទុកដាក់កែលម្អតាមបណ្ដាចំណុចវិធានការដែលគណៈប្រតិភូអធិការកិច្ចហិរញ្ញវត្ថុ បានចាត់វិធានការក្នុងការិយបរិច្ឆេទសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ រួចហើយ។

ប្រតិភូសវនករបានទទួលយកនូវមតិឆ្លើយតបរបស់សវនដ្ឋាន និងបានជម្រាបជូនសវនដ្ឋានថា ប្រតិភូសវនករនឹងត្រូវរៀបចំរបាយការណ៍ស្ដីពីការកែលម្អតាមអនុសាសន៍ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ជ្រាបជារបាយការណ៍ និងមានមតិណែនាំដ៏ខ្ពង់ខ្ពស់។

ជាទីបញ្ចប់ លោកប្រធានមន្ទីរ បានថ្លែងអំណរគុណចំពោះលទ្ធផលការងាររបស់ប្រតិភូ ហើយនឹងបន្តអនុវត្តការងារដែលនៅសេសសល់។

កិច្ចប្រជុំរវាងប្រតិភូសវនកម្មផ្ទៃក្នុង និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង បានចប់សព្វគ្រប់នៅវេលាម៉ោងប្រាំ និងសាមសិបនាទីល្ងាច នាថ្ងៃខែឆ្នាំដដែលក្នុងបរិយាកាសជាភាតរៈ និងស្មារតីទទួលខុសត្រូវខ្ពស់។

**ប្រធានមន្ទីរ** **ប្រធានប្រតិភូ**

លី_សុភា យួន_សុជាតិ

# ឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធទី ១ - ការអនុវត្តអនុសាសន៍សវនកម្មគ្រាមុន

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**     **សវនដ្ឋាន : មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង**

របាយការណ៍សវនកម្ម: **លេខ០១៨ របក/សផក**     កាលបរិច្ឆេទបញ្ចប់របាយការណ៍ស្ថាពរ: **ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣**

*អាទិភាព (ប្រសិនមាន)

- ខ្ពស់: ដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗដែលនាំឱ្យខូចខាតងាយរងគ្រោះ ឬបាត់បង់កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន។
- មធ្យម: ដើម្បីចាត់វិធានការលើបញ្ហាដែលមិនទាន់មានលក្ខណៈល្អប្រសើរ និងដែលសំខាន់សម្រាប់ពង្រឹងប្រព័ន្ធ និងនីតិវិធី។
- ទាប: ពង្រឹងការត្រួតពិនិត្យដែលមានស្រាប់ ឬចងក្រងឯកសារក្នុងទីកន្លែងដែលមិនសូវសំខាន់។

*វិធានការដែលត្រូវអនុវត្តដោយថ្នាក់ដឹកនាំ

*អព: បានអនុវត្តតាមអនុសាសន៍ពេញលេញ និងបានកាត់បន្ថយនូវហានិភ័យឱ្យដល់កម្រិតមួយអាចទទួលយកបាន។

*អខ: បានអនុវត្តតាមអនុសាសន៍ខ្លះ និងហានិភ័យសំណល់ស្ថិតក្នុងកម្រិតមួយមិនអាចទទួលយកបាន។

*មអ: មិនបានអនុវត្តតាមអនុសាសន៍ និងហានិភ័យនៅតែមាន។

*មព: មិនមានហានិភ័យពាក់ព័ន្ធ និងមិនមានហានិភ័យសំណល់ទៀតទេ។

| លេខអនុសាសន៍ | អនុសាសន៍សវនកម្ម | *អាទិភាព (សូមមើល ខ្ពស់/ មធ្យម/ ទាប) | មន្ត្រីទទួលបន្ទុក | កាលបរិច្ឆេទឯកភាពអនុវត្ត | កាលបរិច្ឆេទតាមដាន | វិធានការដោយថ្នាក់ដឹកនាំ (សូមមើល ខាងលើ) | ភស្តុតាងនៃការអនុវត្តដោយថ្នាក់ដឹកនាំ ឬកាលបរិច្ឆេទត្រូវកែសម្រួល និងឯកភាពជាមួយថ្នាក់ដឹកនាំសម្រាប់ការអនុវត្តបន្ត។ |
|---|---|---|---|---|---|---|---|
| ១ | មន្ទីរត្រូវជំរុញការគ្រប់គ្រងសៀវភៅចុះលេខលិខិតចេញឱ្យបានត្រឹមត្រូវគ្រប់ជ្រុងជ្រោយ។ | មធ្យម | ប្រធានមន្ទីរ | | | អ.ព | បានកែលម្អ |
| ២ | មន្ទីរត្រូវជំរុញការគ្រប់គ្រងមន្ត្រីឱ្យបានហ្មត់ចត់ និងត្រឹមត្រូវស្របតាមអនុក្រឹត្យលេខ០៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង | មធ្យម | ប្រធានមន្ទីរ | | | អ.ព | បានអនុវត្ត |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | វត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។ | | | | | | |
| ៣ | មន្ទីរត្រូវជម្រុញការរៀបចំតារាងប្រៀបធៀបកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា។ | មធ្យម | ប្រធានមន្ទីរ | | | អ.ព | បានអនុវត្ត |
| ៤ | មន្ទីរត្រូវខិតខំជួយជំរុញបន្ថែម និងពន្យល់ណែនាំដល់ប្រជាពលរដ្ឋដើម្បីមកស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន-បិទការដ្ឋាននៅពេលសំណង់រួចរាល់។ | មធ្យម | ប្រធានមន្ទីរ | | | អ.ព | បាននឹងកំពុងអនុវត្ត |

រៀបចំដោយៈ លោក **នី ម៉ាល័យ** កាលបរិច្ឆេទៈ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤

ត្រួតពិនិត្យដោយៈ លោក **ហេង វាសនា** កាលបរិច្ឆេទៈ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤

ខេត្តកំពង់ឆ្នាំង, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤

**ប្រធានមន្ទីរ**

**លី សុភា**

- ខ្ពស់: ដើម្បីកាត់បន្ថយហានិភ័យសំខាន់ៗដែលនាំឱ្យខូចខាត ងាយរងគ្រោះ ឬបាត់បង់កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន។
- មធ្យម: ដើម្បីចាត់វិធានការលើបញ្ហាដែលមិនទាន់មានលក្ខណៈល្អប្រសើរ និងដែលសំខាន់ពង្រឹងប្រព័ន្ធ និងនីតិវិធី
- ទាប: ពង្រឹងការត្រួតពិនិត្យដែលមានស្រាប់ឬចងក្រងឯកសារក្នុងទីដែល មិនសូវសំខាន់
- អ.ព: អនុវត្តតាមអនុសាសន៍ឱ្យបានពេញលេញ និងកាត់បន្ថយនូវហានិភ័យឱ្យដល់កម្រិតមួយអាចទទួលយកបាន ។

## ២.ឧបសម្ព័ន្ធទី ២ -ផែនការសកម្មភាពកែលម្អ

របាយការណ៍ : សវនកម្មនៅ **មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ការិយបរិច្ឆេទ២០២២**

របាយការណ៍លេខ: ...០១៩... /របក ចុះថ្ងៃទី...២៧.... ខែ...កុម្ភៈ...ឆ្នាំ២០២៣

| អនុសាសន៍លេខ | សកម្មភាពដែលថ្នាក់ដឹកនាំបានឯកភាព | អាទិភាព* | មន្ត្រីទទួលបន្ទុក | កាលបរិច្ឆេទឯកភាពបញ្ចប់ការអនុវត្ត |
|---|---|---|---|---|
| **១.ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ** | | | | |
| ក. មន្ទីរត្រូវជំរុញការគ្រប់គ្រងសៀវភៅចុះលេខលិខិតចេញឱ្យបានត្រឹមត្រូវគ្រប់ជ្រុងជ្រោយ។ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរ នឹងធ្វើការណែនាំមន្ត្រីគ្រប់គ្រងការងាររដ្ឋបាលត្រូវចុះខ្លឹមសារលិខិតនៅក្នុងសៀវភៅចុះលិខិតចេញ បានត្រឹមត្រូវ និងពេញលេញ។ |
| ខ. មន្ទីរត្រូវជំរុញការគ្រប់គ្រងមន្ត្រីឱ្យបានហ្មត់ចត់ និងត្រឹមត្រូវស្របតាមអនុក្រឹត្យលេខ០៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរបានធ្វើលិខិតណែនាំដល់សាម៉ីខ្លួន ហើយសាម៉ីខ្លួនចូលធ្វើការងារជាធម្មតាវិញ។ |

| ២.ផ្នែកអនុលោមភាព | | | | |
|---|---|---|---|---|
| ក.មន្ទីរ ត្រូវជម្រុញការរៀបចំតារាងប្រៀបធៀបកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា។ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរ នឹងរៀបចំធ្វើតារាងប្រៀបធៀបកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា។ |
| ខ.មន្ទីរត្រូវខិតខំជួយជំរុញបន្ថែម និងពន្យល់ណែនាំដល់ប្រជាពលរដ្ឋដើម្បីមកស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន-បិទការដ្ឋាននៅពេលសំណង់រួចរាល់។ | អ.ព | មធ្យម | ប្រធានមន្ទីរ | មន្ទីរ នឹងជំរុញបន្ថែម និងពន្យល់ណែនាំដល់ប្រជាពលរដ្ឋដើម្បីមកស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន និងបិទការដ្ឋាននៅពេលសំណង់រួចរាល់។ |

**ប្រធានមន្ទីរ**

លី_សុភា

**ប្រតិភូសវនករ**

យួន_សុជាតិ